# អំពីឈ្មោះ "របងរមាស"

របងរមាស គឺជាឈ្មោះក្រុមប្រាសាទមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុក មានចម្ងាយប្រមាណ២គីឡូម៉ែត្រខាងជើងក្រុមប្រាសាទសំខាន់ៗទាំងបី និងស្ថិតនៅខាងលិចក្រុមប្រាសាទស្រីគ្រប់ល័ក្ខណចម្ងាយប្រមាណ ១០០ម៉ែត្រ។ នៅក្នុងក្រុមប្រាសាទរបងរមាសមានប្រាសាទសរុបចំនួន ៩ ដែលក្នុងនោះមានប្រាសាទចំនួន ៨ សាងអំពីឥដ្ឋ និងប្រាសាទចំនួន១សាងអំពីថ្មបាយក្រៀម ហើយពល់សំណង់ទាំងអស់សុទ្ធសឹងទំនងសាងឡើងនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៤៩) ដែលគេអាចដឹងតាមរយៈតឹកតាងសិលាចារឹកមួយនៅតួប៉ម K.4 ចុះបញ្ជីលេខ K.153 (សព្វថ្ងៃរក្សាទុកនៅសារមន្ទីរខេត្តកំពង់ធំ)[១] (រូបលេខ១-២)។ ក្រុមប្រាសាទនេះចាប់ផ្ដើមមានការសិក្សាស្រាវជ្រាវដំបូងតាំងពីឆ្នាំ ១៩០៧ ដោយលោក George Morand[២] និងក្រោយមកនៅឆ្នាំ១៩១៣ លោក Henri Parmentier បានសិក្សាលម្អិតជាងមុន[៣]។ អ្នកប្រាជ្ញផ្នែកប្រវត្តិសិល្បៈដែលធ្លាប់បានសិក្សាកន្លងមក បានកត់ត្រាឈ្មោះក្រុមប្រាសាទនេះតាមសំនៀងអ្នកស្រុកហៅថា "របងរមាស" ប៉ុន្តែគេពុំធ្លាប់សិក្សាលម្អិតអំពីឈ្មោះនេះទេ។ កន្លងមកកាលណាគេឮឈ្មោះនេះ គេតែងនឹកស្រមៃថាប្រាសាទនេះពីមុនមកជាកន្លែងមានចិញ្ចឹមសត្វរមាស ឬតម្កល់សត្វរមាស តែបើយកមកគិតឡើងវិញទៅទំនងពុំដូច្នេះឡើយ។ តើឈ្មោះ "របងរមាស" មានន័យយ៉ាងណា?

ឈ្មោះ "របងរមាស" ផ្សំឡើងអំពីពាក្យចំនួនពីរគឺ "របង" និង "រមាស"។ នៅក្នុងវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យពន្យល់ថា "របង" គឺជាចំណារមាំធ្វើរាំងភូមិ រាំងដំណាលជាដើមសម្រាប់ការពារមិនឲ្យសត្វឬមនុស្សចូលបាន (របងភូមិ របងចម្ការ)។[៤] ចំណែកពាក្យ "រមាស" វិញគឺជាសត្វចតុប្បាទព្រៃមួយប្រភេទ ពងរលមាំសំបុកពោះទ្រយុកស្រដៀងនឹងជ្រូកស្រុក ប្រអប់ស្រដៀងនឹងដំរី ក្បាលតូចខ្ទឹមមិនសមនឹងមាត្រ ស្បែកក្រាស់ មានកុយនៅចំពីលើច្រមុះ ជាសត្វសាហាវ បរិភោគអនុបាទិន្នកជាតិជាអាហារ[៥] សូមបញ្ជាក់ថា ការហៅឈ្មោះប្រាសាទនេះថា "របងរមាស" ដូច្នេះ គឺគេសំដៅទៅលើប្រាសាទដែលសាងឡើងអំពីថ្មបាយក្រៀម មានរាងជាអគារមានលំនាំជាបន្ទប់វែង រាងបួនជ្រុងទ្រវែង ហើយមានសសរពីរជួរស្របនឹងជញ្ជាំងខាងត្បូង និងខាង

---

[១] Coedès 1953: 194.

[២] Morand 1907: 25-26.

[៣] Parmentier 1913: 29, 31-32.

[៤] ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧: ៥៦៤។

[៥] ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧: ៥៦៤។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ជើង ដែលសសរទាំងពីរជួរខណ្ឌចែកដោយបន្ទប់វែងមួយ បង្កើតឱ្យមានល្វែងធំមួយនៅកណ្ដាល និងអមដោយល្វែងតូចៗពីរនៅសងខាង ព្រមទាំងមានទ្វារចូលនៅទិសខាងកើតនិងខាងលិចមានតួលយចេញមកក្រៅដែលអមដោយសសរវែង និងមានទ្វារចូលបួនផ្សេងទៀតនៅតាមជញ្ជាំងខាងជើងនិងខាងត្បូង (រូបលេខ២៣)។[៦] ហេតុដូច្នេះ បើយើងយកអត្ថន័យតាមវចនានុក្រមខ្មែរមកផ្សំបញ្ចូលគ្នា យើងនឹងបានន័យរួមមួយដោយសង្ខេបថា “របងដែលព័ទ្ធសត្វរមាស”។

នៅក្នុងអត្ថបទនេះ យើងស្នើថាឈ្មោះ “របង់រមាស” ទំនងពុំមានន័យបែបនោះឡើយ។ ប៉ុន្តែយើងស្នើថា ការដែលគេហៅថា “របង់រមាស” ដូច្នេះ មកពីគេសំដៅទៅលើសសររបស់ប្រាសាទដែលសាងអំពីថ្មបាយក្រៀមមានរាងដូចជារបងមួយជួរ ហើយចំណែកពាក្យ “រមាស” វិញ គឺទំនងគេសំដៅដល់ពណ៌របស់ថ្មបាយក្រៀមដែលមានពណ៌ក្រហមក្រម៉ៅ។ ពាក្យ “រមាស” ជាពាក្យក្នុងភាសាខ្មែរដែលមនុស្សម្នានៅប្រើប្រាស់ច្រើន ជាពិសេស អ្នកស្រុករស់នៅតំបន់ជនបទនានាក្នុងខេត្តកំពង់ធំ ដូចជាស្រុកសណ្ដាន់ជាដើម។ ឧទាហរណ៍៖ កាលណាគេពាក់អាវដល់បែកញើសខ្លាំង នៅលើកអាវនឹងប្រឡាក់ក្អែលឡើងពណ៌ក្រហមក្រម៉ៅ ឬពណ៌ខ្មៅ គេច្រើនតែនិយាយថា “*ពាក់អាវឡើងរមាសហើយ*”។ ក្រៅពីនេះ បើកាលណាវត្ថុប្រើប្រាស់ផ្សេងៗប្រចាំថ្ងៃឡើងអាចម៍ថៃ ចេញពណ៌ក្រហមក្រម៉ៅ ឬពណ៌ខ្មៅ ក៏គេហៅថា “រមាស” ដូចគ្នា (សសរផ្ទះឡើងរមាស, ដងចបឡើងរមាស ជាដើម)។ ដូច្នេះ ឈ្មោះប្រាសាទដែលអ្នកស្រុកហៅថា “របង់រមាស” ទំនងមានន័យសំដៅដល់សសរប្រាសាទជាជួរដែលមានពណ៌រមាស (ពណ៌ក្រហមក្រម៉ៅ)។

ការគិតដូច្នេះពុំមែនមានតែនៅតំបន់សំបូរព្រៃគុកមួយប៉ុណ្ណោះទេ ដ្បិតយើងឃើញមានឧទាហរណ៍ផ្សេងៗទៀតនៅតំបន់អង្គរ ឬនៅភ្នំគូលែនជាដើម។ នៅតំបន់អង្គរ មានប្រាសាទមួយដែលដើរតួនាទីជាក្រោលដាក់សត្វដំរី ឬក្រោលផ្សាំងសត្វដំរី មានឈ្មោះថា “ក្រោលរមាស” ហើយជាឈ្មោះដែលគេហៅតគ្នាមក និងស្គាល់តាមរយៈរឿងព្រេងនិទាន។[៧] សំណង់នោះមានរាងប្រហែលពងក្រពើ ធ្វើអំពីថ្មបាយក្រៀម ម៉្លោះហើយយើងគិតថាករណីនេះមិនខុសពីនៅសំបូរព្រៃគុកទេ ពោល គឺគេហៅ “ក្រោល” សំដៅដល់រាងប្រាសាទ និង “រមាស” សំដៅដល់ពណ៌ថ្មបាយក្រៀមដែលមានពណ៌ក្រម៉ៅ (រូបលេខ២៤)។ ចំណែក ប្រាសាទក្រោលរមាស នៅលើភ្នំគូលែន ក៏មិនខុសគ្នាដែរ ជាប្រាសាទដែលសាងអំពីថ្មបាយក្រៀម មានកំពែងព័ទ្ធជុំវិញ (រូបលេខ២៥)។

---

[៦] កែវ គីណាល់ ២០០៤: ៧៧-៧៨។

[៧] ស៊ិន ប៊ុណ្ណា ២០១៦: ៨។

អត្ថបទដោយៈ ម៉ង់ រ៉ាលី

*ជារួមមក យើងសន្និដ្ឋានថា "របងរមាស" គឺជាឈ្មោះដែលអ្នកស្រុកហៅសំដៅដល់តួប៉មប្រាសាទមានរាងបួនជ្រុងទ្រវែងធ្វើអំពីបាយក្រៀម ដែលចង់មានន័យថា "របងដែលមានពណ៌រមាស (ពណ៌ក្រហមក្រម៉ៅ)។ ទោះបីជាយ៉ាងណា នេះជាការស្នើបឋមមួយ ទាមទារឲ្យមានការសិក្សាវែងឆ្ងាយតទៀត។*

## ឯកសារយោង

*កែវ គីណាល់*

*២០០៤, "ស្ថាបត្យកម្មក្រុមប្រាសាទរបងរមាស សម្បូណ៌ព្រៃគុក", ព្រឹត្តិបត្រនិស្សិតមហាវិទ្យាល័យបុរាណវិទ្យា លេខ៣ ភ្នំពេញ*

*ស៊ិន ប៊ុណ្ណា*

*២០១៦, "តួនាទីប្រាសាទក្រោលដំរី", ភ្នំពេញ*

*ពុទ្ធសាសនបណ្ឌិត*

*១៩៦៧, "**វចនានុក្រមខ្មែរ**", ភ្នំពេញ*

**Coedès, George**

1953, "*Inscription du Cambodge*", Vol V, Hanoi

**Morand, George**

1907, *Notes et images pour mieux faire connaître les monuments et les arts des anciennes civilizations du Cambodge et du Laos,* Carqueirance (Var) : 2 fasc. (12p.), pl (C.R. par Finot, 1907).

**Parmentier, Henri**

1913, "Complément à l'Inventaire descriptif des monuments du Cambodge", *BEFEO,* Tome 13, Paris.

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*



*រូបលខ២១៖ ប្រាសាទរបងមាស តួប៉ម K6 (មើលពីមុខអាគ្នេយ៍)*



*រូបលេខ២២៖ ប្រាសាទរបងមាស តួប៉ម K7 (មើលពីមុខឦសាន)*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៣៖ ប្រាសាទរបងមាសធ្វើអំពីថ្មបាយក្រៀម តួប៉ម K8 (មើលពីមុខខ្លឿសាន)



រូបលេខ២៤៖ ប្រាសាទក្រោលរមាស នៅតំបន់អង្គរ ធ្វើអំពីថ្មបាយក្រៀម (រូបថត៖ ស៊ិន ប៊ុណ្ណា)



*រូបលេខ៥៖ ប្រាសាទក្រោលរមាស នៅលើភ្នំគូលែនធ្វើអំពីថ្មបាយក្រៀម (រូបថត៖ ងិន សារុន)*

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី